ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមុខងារសាធារណៈ
លេខ : ✓ មស.

លិខិតជូនពរ និងអបអរសាទរ

សូមគោរពជូន

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

សម្តេចអគ្គមហាសេនាបតីតេជោ ជាទីគោរពដ៏ខ្ពង់ខ្ពស់

យើងខ្ញុំទាំងអស់គ្នាជាថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃក្រសួងមុខងារសាធារណៈ សូមសម្តែងនូវការអបអរសាទរ និងមោទនភាពយ៉ាងក្រៃលែងក្នុងឱកាសដែល **សម្តេចតេជោនាយករដ្ឋមន្ត្រី** បានបង្កើតស្នាដៃជាប្រវត្តិសាស្ត្រមួយទៀត គឺការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ ដែលកំណត់ឱ្យថ្នាក់ដឹកនាំកំពូលរបស់កម្ពុជាមានសញ្ជាតិខ្មែរតែមួយគត់។

ក្នុងឱកាសដ៏ឧត្តុង្គឧត្តមថ្លៃថ្លានេះ យើងខ្ញុំសូមសម្តែងនូវសេចក្តីគោរពដឹងគុណដ៏ស្មោះអស់ពីដួងចិត្តចំពោះគំរូវីរភាពដ៏ផ្ទើមរបស់ **សម្តេចតេជោ** ដែលបានរួមចំណែកតស៊ូរំដោះប្រទេសជាតិ ស្វះស្វែងរកសន្តិភាព បង្រួបបង្រួមជាតិ កសាង និងអភិវឌ្ឍប្រទេសជាតិឱ្យមានការរីកចម្រើនដូចបច្ចុប្បន្ន។

រាជរដ្ឋាភិបាលក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចតេជោ** បានដឹកនាំនាវាកម្ពុជាសម្រេចបាននូវសមិទ្ធផលដ៏ត្រចះត្រចង់ជាបន្តបន្ទាប់ ថែរក្សាបាននូវសុខសន្តិភាព អធិបតេយ្យភាព បូរណភាពទឹកដីដ៏រឹងមាំ ឯកភាពជាតិ ស្ថិរភាពជាតិ និងការរីកចម្រើនជឿនលឿនលើគ្រប់វិស័យ ដែលទទួលបាននូវកិត្យានុភាពដ៏ស័ក្តិសម ទាំងក្នុងក្របខណ្ឌតំបន់ និងលើឆាកអន្តរជាតិ ពិសេសក្នុងការប្រយុទ្ធពុះពារទ្រោលសភាពការណ៍ដែលបង្កឡើងដោយវិបត្តិកូវីដ-១៩ ដើម្បីបុព្វហេតុសុខសន្តិភាព សុខុមាលភាព វិបុលភាព និងវឌ្ឍនភាពរបស់ប្រទេសជាតិ និងប្រជាជនយើង។

យើងខ្ញុំសូមបួងសួងចំពោះគុណបុណ្យព្រះរតនត្រ័យ និងវត្ថុស័ក្តិសិទ្ធិក្នុងលោក សូមប្រោសប្រទានជូន **សម្តេចតេជោនាយករដ្ឋមន្ត្រី និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត ព្រមទាំងបុត្រា បុត្រី ចៅប្រុស ចៅស្រី** សូមបានប្រកបដោយពុទ្ធពរទាំងបួនប្រការ គឺអាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូម **សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** មេត្តាទទួលនូវសេចក្តីគោរពដ៏ជ្រាលជ្រៅ និងខ្ពង់ខ្ពស់បំផុតពីយើងខ្ញុំ៕

ថ្ងៃ ច័ន្ទ ៤ រោច ខែ អស្សុជ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែ តុលា ឆ្នាំ២០២១

តំណាងថ្នាក់ដឹកនាំ និងមន្ត្រីរាជការ នៃក្រសួងមុខងារសាធារណៈ
រដ្ឋមន្ត្រី

ព្រុំ-សុខា